# ព្រះនៃ
# សេចក្ដីសង្ឃឹម

ព្រះនៃសេចក្ដីសង្ឃឹមបានប្រទានឲ្យខ្ញុំគ្រប់អស់ទាំងសេចក្ដីអំណរ និង សេចក្ដីសុខសាន្តដ៏ពោរពេញ ដោយសារសេចក្ដីជំនឿ ប្រយោជន៍ឲ្យបាន សេចក្ដីសង្ឃឹមជាបរិបូរ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ។(១)

ខ្ញុំបានរត់ទៅរកទ្រង់ដែលជាទីជ្រកកោន ដូច្នេះខ្ញុំមានការលួងលោមចិត្តជាខ្លាំង ដើម្បីឈោងចាប់សេចក្ដីសង្ឃឹមដែលបានកំណត់មុនខ្ញុំ។ ក្ដីសង្ឃឹមនេះខ្ញុំមានដូចជាយុថ្កាមួយនៃព្រលឹងទាំងប្រាកដជាថានឹងកាន់ខ្ជាប់ខ្ជួន។ (២)

សេចក្ដីជំនឿ នោះគឺជាចិត្តដែលខ្ញុំដឹងជាក់ថានឹងបានដូចសង្ឃឹម។(៣)

ខ្ញុំជឿសេចក្ដីនេះជាយ៉ាងជាក់លាក់ថា ព្រះអង្គដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងខ្ញុំទ្រង់នឹងធ្វើឲ្យកាន់តែពេញខ្នាតឡើងទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ។ (៤)

ឯសេចក្ដីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ [២៣] សេចក្ដីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្ដីស្មោះត្រង់របស់ទ្រង់ធំណាស់ ព្រលឹងខ្ញុំបានពោលថា ព្រះយេហូវ៉ាជាចំណែកនៃខ្ញុំ ហេតុនោះខ្ញុំនឹងសង្ឃឹមដល់ទ្រង់ ព្រះយេហូវ៉ាទ្រង់ល្អដល់ខ្ញុំ ដែលរង់ចាំទ្រង់ គឺដល់ព្រលឹងនៃខ្ញុំ ដែលស្វែងរកទ្រង់។(៥)

**អាម៉ែន!**

(១) រ៉ូម ១៥: ១៣
(២) ហេព្រើរ ៥: ១៨-១៩
(៣) ហេព្រើរ ១១: ១
(៤) ភីលីព ១: ៦
(៥) បរិទេវ ៣: ២២ខ-២៥

**រ៉ូម ១៥: ១៣** ឥឡូវនេះ សូមព្រះនៃសេចក្តីសង្ឃឹមប្រទានឲ្យអ្នករាល់គ្នាបានគ្រប់អស់ទាំងសេចក្តីអំណរ និងសេចក្តីសុខសាន្តដ៏ពោរពេញ ដោយសារសេចក្តីជំនឿ ប្រយោជន៍ឲ្យបានសេចក្តីសង្ឃឹមជាបរិបូរ ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។

**ហេព្រើរ ៦: ១៨-១៩** ដើម្បីឲ្យយើងរាល់គ្នា ដែលបានរត់មកចាប់កាន់សេចក្តីសង្ឃឹម ដែលដាក់នៅមុខយើង ទុកជាទីជ្រកកោន បានសេចក្តីកំឡាចិត្តឡើងជាខ្លាំង ដោយសារសេចក្តីទាំង២មុខនេះដ៏មិនចេះប្រែប្រួល ដែលខាងឯសេចក្តីទាំង២នោះ ព្រះទ្រង់កុហកពុំបានទេ [១៩] យើងខ្ញុំមានសេចក្តីសង្ឃឹមនោះ ទុកដូចជាយុថ្កានៃព្រលឹងដ៏ជាប់លាប់មាំមួន ដែលចូលទៅខាងក្នុងនៃវាំងនន ។

**ហេព្រើរ ១១: ១** រីឯសេចក្តីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថានឹងបានដូចសង្ឃឹម ជាសំគាល់ពីការដែលមើលមិនឃើញ ។

**ភីលីព ១: ៦** ខ្ញុំជឿសេចក្តីនេះជាយ៉ាងជាក់ថា ព្រះអង្គដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឲ្យកាន់តែពេញខ្នាតឡើងទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ ។

**បរិទេវ៣:២២ខ-២៥** ឯសេចក្តីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ [២៣] សេចក្តីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្តីស្មោះត្រង់របស់ទ្រង់ធំណាស់ [២៤] ព្រលឹងខ្ញុំបានពោលថា ព្រះយេហូវ៉ាជាចំណែកនៃខ្ញុំ ហេតុនោះខ្ញុំនឹងសង្ឃឹមដល់ទ្រង់ [២៥] ព្រះយេហូវ៉ាទ្រង់ល្អដល់អស់អ្នកដែលរង់ចាំទ្រង់ គឺដល់ព្រលឹងនៃអ្នកណាដែលស្វែងរកទ្រង់។

**បកប្រែដោយ: ONE -2- ONE CAMBODIA**
**អាស័យដ្ឋានៈ # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC14